## ជំពូកទី១
## អំពី
## ប្រវត្តិ និងគោលការណ៍

**មាត្រា ១.**

មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាពត្រូវបានបង្កើតដោយក្រុមមនុស្សមួយក្រុមដែលធ្លាប់បំរើការងារនៅក្នុងចលនាយុវជនចាប់តាំងពីឆ្នាំ១៩៩២ ។ ក្រុមនេះមានគោលគំនិតពង្រឹងចលនាមនុស្សថ្មីអោយចូលរួមស្ថាបនាសង្គមលើផ្នែកសិទ្ធិមនុស្ស ប្រជាធិបតេយ្យ សន្តិភាព សុខុមាលភាព និងសេរីភាពនៅក្នុងសង្គមកម្ពុជា ។

ការបង្កើតមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាពនេះទៀតសោតគឺដើម្បីចូលរួមដោះស្រាយនូវបញ្ហាមួយចំនួនដែលកំពុងតែញាំញីប្រទេសកម្ពុជាជាអាទិ៍ គឺភាពក្រីក្រ អំពើពុករលួយ អំពើនីទណ្ឌភាព ការបាត់បង់ដីធ្លី អំពើជួញដូរស្ត្រីនិងកុមារ គ្រឿងញៀន និងកង្វះការធានាសុខភាពសំរាប់ប្រជាពលរដ្ឋ...។ល។

ការប្រឈមមុខដ៏ធ្ងន់ធ្ងរទាំងនេះបើមិនរិះរកមធ្យោបាយបង្ការ និងទប់ស្កាតវានឹងបង្កមហន្តរាយយ៉ាងធ្ងន់ធ្ងរដល់សង្គមកម្ពុជាទៅថ្ងៃអនាគតព្រមទាំងរុញច្រានប្រទេសកម្ពុជាឲ្យធ្លាក់ចូលទៅក្នុងភាពក្រីក្រកាន់ជ្រៅទៅៗ ។

គំនិតថ្មីមើលឃើញថា វិធីដ៏មានប្រសិទ្ធិភាព គឺត្រូវមានក្រុមមនុស្សដែលមានការប្តេជ្ញាចិត្តខ្លាំងក្លាក្នុងការចូលរួមដោះស្រាយទប់ស្កាត់ទើបអាចនាំមកនូវសង្គមមួយ ដែលមានការគោរពគ្នាយោគយល់អធ្យាស្រ័យគ្នាមានការធានាសុខភាពនិងគ្មានអំពើពុករលួយ។ ដោយហេតុថា សង្គមកម្ពុជាមានបញ្ហាជាច្រើនដែលត្រូវដោះស្រាយទើប "មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព "ត្រូវបានបង្កើតឡើងនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៤ ក្រោមការផ្តួចផ្តើមរបស់អតីត និងសមាជិកសមាជិកាសមាគមយុវជនខ្មែរដើម្បីបន្តឧត្តមគតិនៃការលើកកំពស់សេរីភាព និងតម្លាភាពនៅក្នុងសង្គមកម្ពុជាជាបន្តទៀត ។

## ជំពូកទី២
## អំពីឈ្មោះ និងផ្លាកសញ្ញា

**មាត្រា ២.**

**ក-អំពីឈ្មោះ**

អង្គការមានឈ្មោះជាផ្លូវការថា " មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព " ជាអក្សរកាត់ " មជ្ឈមណ្ឌល-ភីឌីភី " និងជាភាសាអង់គ្លេស "People Center For Development and Peace" និង ជាអក្សរកាត់ " PDP-Center"

**ខ-អំពីផ្លាកសញ្ញា**

ផ្លាកសញ្ញារបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពមានដូចតទៅ ៖

- ផែនទីប្រទេសកម្ពុជាដែលតំណាងអោយបូរណភាពទឹកដី និងជីវិតរស់នៅរបស់ប្រជាពលរដ្ឋគ្រប់ៗគ្នានៅលើទឹកដីសុវណ្ណភូមិនេះ ។
- នៅខាងក្រៅផែនទីមានសរសេរអក្សរថា "មជ្ឈមណ្ឌល " ដែលតំណាងអោយការជួបជុំការពួតផ្តុំគំនិតបញ្ញានិងការរួបរួមកំលាំងគ្នាដើម្បីអភិវឌ្ឍន៍សង្គមកម្ពុជាឲ្យសំបូររុងរឿង ។
- នៅក្នុងផែនទីមានអក្សរកាត់ថា " ភីឌីភី " ដែលរចនាអក្សរទៅតាមរចនាបថរបស់ខ្មែរយើងតំណាងអោយការមិនចេះសាបសូន្យនៃព្រលឹងជាតិខ្មែរ ដែលតែងតែឆ្លាក់នៅជាប់ជានិច្ចនៅលើទឹកដីរបស់ខ្លួន ។
- នៅខាងក្រោមផែនទីមានអក្សរកាត់ជាភាសាអង់គ្លេសថា PDP-Center ដែលជានិម្មិតរូបនៃទំនាក់ទំនងអន្តរជាតិ ។

## ជំពូកទី៣
## អំពី
## ទស្សនវិស័យ បេសកកម្ម គោលបំណង គុណតម្លៃ និងទិសដៅ

មាត្រា ៣.

មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពមានទស្សនវិស័យ បេសកកម្ម គោលបំណង និងទិសដៅដូចខាងក្រោម ៖

**ក. ទស្សនវិស័យ:**

មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព គឺចង់ឃើញសង្គមមួយប្រកបទៅដោយភាពរុងរឿង និង ឧដុមរម្យនា។

**ខ- បេសកកម្ម:**

បេសកកម្មរបស់យើង គឺដើម្បីស្ថាបនាគំនិតប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស តម្លាភាព សន្តិភាព ព្រមទាំងការលើកស្ទួយសុខភាពនៅក្នុងចំណោមប្រជាពលរដ្ឋ និងយុវជនទាំងនៅទីក្រុង និងទីជនបទ ។

**គ- គោលបំណង:**

បង្កើតសង្គមប្រជាធិបតេយ្យសំរាប់ខ្មែរជំនាន់ថ្មីប្រកបដោយការគោរពសិទ្ធិមនុស្ស និងតម្លាភាព ព្រមទាំងលើកកំពស់សុខុមាលភាពសង្គម ។

**ឃ. គុណតម្លៃ:**

គុណតម្លៃរបស់មជ្ឈមណ្ឌលភីឌីភីមានដូចខាងក្រោមៈ

យើងអនុវត្តគោលការណ៍ព្រីល "PRRIL" នៅក្នុងការងារគ្រប់ទីកន្លែងរបស់យើងមានៈ

- **សន្តិវិធីៈ** នៅក្នុងដំណើរការតស៊ូមតិ និងដោះស្រាយទំនាស់របស់យើង យើងត្រូវតែមានការជឿជាក់ អត់ធ្មត់នៅក្នុងការចែករំលែក សម្របសម្រួល និង សម្រុះសម្រួល ដើម្បីអោយមានសាមគ្គីភាព ។
- **ការគោរពៈ** យើងអោយតម្លៃទៅលើគំនិតយោបល់ ការបញ្ចេញមតិនិងការសម្រេចចិត្តរបស់បុគ្គលិក សហគមន៍គោលដៅ និងដៃគូរ ។
- **ភាពជាគំរូៈ** យើងមិនអនុញ្ញាតឲ្យបុគ្គលិក ឬសមាជិកណាម្នាក់ប្រើប្រាស់ ឬជួញដូរគ្រឿងញៀនខុសច្បាប់ និងលើកទឹកចិត្តពួកគេឲ្យវៀរចាកការប្រើប្រាស់គ្រឿងស្រវឹងដើម្បីធានាដល់សិទ្ធិសុខភាពរបស់ពួកគេ
- **ឯករាជភាពៈ** យើងមិនចូលរួមបម្រើសកម្មភាពគណបក្សនយោបាយ តែយើងក៏មិនរើសអើងប្រឆាំងនឹងគណបក្សនយោបាយណាមួយឡើយ ។
- **ការស្តាប់ដោយយកចិត្តទុកដាក់ៈ** យើងត្រូវតែស្តាប់ឲ្យបានច្បាស់ នូវការលើកឡើងរបស់បុគ្គលិក សហគមន៍គោលដៅ និងដៃគូរនានា។

**ង-ទិសដៅ:**

- ស្ថាបនាគំនិតប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស តម្លាភាព និងអហឹង្សាសកម្ម នៅក្នុងចំណោម ប្រជាពលរដ្ឋ និងយុវជននៅក្នុងប្រទេសកម្ពុជា។
- កាត់បន្ថយការប្រើប្រាស់គ្រឿងញៀនអោយមានកំរិតអបប្បរិមារព្រមទាំងលើកកំពស់សុខុមាលភាពប្រជាពលរដ្ឋ និងយុវជនកម្ពុជា។
- ជំរុញស្ថាប័នរដ្ឋឲ្យបង្កើត និងកែលំអគោលនយោបាយរដ្ឋដើម្បីទប់ស្កាត់ផលប៉ះពាល់ដែលបណ្តាលមកពីសារធាតុញៀន ការបំភ្លេចបំផ្លាញសិទ្ធិមូលដ្ឋាន និងការបំបិទសិទ្ធិបញ្ចេញបតិរបស់ប្រជាពលរដ្ឋ និងយុវជន។
- រៀបចំបណ្តាញ និងចង់ក្រងសហគមន៍ដើម្បីការពារផលប្រយោជន៍ប្រជាពលរដ្ឋនៅមូលដ្ឋាន ។
- ធ្វើទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការណ៍ជាមួយអង្គការជាតិ និងអន្តរជាតិនៅជុំវិញពិភពលោក ដើម្បីចែកចាយពត៌មានឲ្យគ្នាទៅវិញទៅមក និងពង្រីកបណ្តាញតស៊ូមតិ ។

## ជំពូកទី៤
## អំពី
## សមាជិកភាព

### មាត្រា ៤

មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពមានសមាជិកបីប្រភេទគឺ:

**ក. សមាជិកស្ថាបនិក ៖**គឺជាសមាជិក ដែលបានចូលរួមបង្កើតមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព ។

**ខ. សមាជិកជាយុវជន ៖** យុវជន សិស្ស និស្សិត ដែលមានអាយុពី ១៥ឆ្នាំដល់៣០ឆ្នាំ អាចដាក់ពាក្យសុំចូលជាសមាជិកមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព ។

**គ. សមាជិកជាប្រជាពលរដ្ឋ:** គឺជាប្រជាពលរដ្ឋដែលមានវ័យចាប់ពី៣១ឆ្នាំឡើងទៅ ។សមាជិកទាំងអស់ត្រូវឈរលើគោលការណ៍មិនប្រើប្រាស់គ្រឿងញៀន និងប្រឆាំងនឹងគ្រឿងញៀនគ្រប់ប្រភេទរួមទាំងស្រា បារីផង ។

### មាត្រា ៥

សមាជិកទាំងអស់ត្រូវបង់ថវិកាចំនួន ១.០០០ រៀល (មួយពាន់រៀលគត់) ក្នុងមួយឆ្នាំ។

### មាត្រា ៦

សមាជិករបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាពមានសិទ្ធិ និងករណីយកិច្ចដូចតទៅ:

- ចូលរួមគ្រប់សកម្មភាពរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពដោយស្ម័គ្រចិត្ត
- ចូលរួមផ្តល់យោបល់ដើម្បីរៀបចំសកម្មភាពការងាររបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋ ដើម្បីអភិវឌ្ឍន៍ និងសន្តិភាព
- មានសិទ្ធិបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាភិបាលនិងឈរឈ្មោះជាបេក្ខជនប្រធាន
- មានសិទ្ធិចូលរួមមហាសន្និបាត និងធ្វើការសំរេចចិត្តដើម្បីវឌ្ឍន៍ភាពមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព

- សមាជិកទាំងអស់ត្រូវតែគោរពបទបញ្ញាផ្ទៃក្នុងនិងលក្ខន្តិកៈរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋ ដើម្បីអភិវឌ្ឍន៍និងសន្តិភាព និង
- ចូលរួមសកម្មភាពរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពទាំងកំលាំងកាយ និង កំលាំងចិត្ត។

**មាត្រា ៧**

មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពនឹងប្រឹងប្រែងយកអស់ពីលទ្ធភាពដើម្បីជួយឧបត្ថម្ភជ្រោមជ្រែងនិងសហាការបណ្តុះបណ្តាលសមាជិកអោយមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**មាត្រា ៨**

សមាជិកណាម្នាក់ដែលប្រព្រឹត្តផ្ទុយពីលក្ខន្តិកៈ និងបទបញ្ញត្តិនានាដែលលើកឡើងដោយមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព នឹងត្រូវដកហូតសមាជិកភាព។

## ជំពូកទី៥
## អំពី
## មហាសន្និបាត

**មាត្រា ៩**

មហាសន្និបាត គឺជាអង្គការសំរេចចិត្តកំពូលរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព ។មហាសន្និបាតមានពីរប្រភេទគឺៈ

**១. មហាសន្និបាតសាមញ្ញៈ**គឺត្រូវប្រារព្ធធ្វើឡើងជាទៀងទាត់រៀងរាល់បួនឆ្នាំម្តង ។ មហាសន្និបាតសាមញ្ញ គឺសំដៅជ្រើសរើសប្រធានម្ឈមណ្ឌល សមាជិកក្រុមប្រឹក្សាភិបាល រាយការណ៍ពីសកម្មភាពការងាររយៈពេលបួនឆ្នាំ ធ្វើរបាយការណ៍ថវិកា ធ្វើវិសោធនកម្មលក្ខន្តិកៈ អនុម័តគំរោងផែនការសកម្មភាពមេ និងការចោទ-ឆ្លើយក្នុងករណីមានការសង្ស័យ ឬមន្ទិលណាមួយពាក់ព័ន្ធនឹងដំណើរការរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព។ មហាសន្និបាតសាមញ្ញត្រូវតែរៀបចំឡើងនៅរៀងរាល់ចុង ខែវិច្ឆិកា នៃឆ្នាំទី៤ក្នុងអណត្តិនីមួយៗ ប៉ុន្តែកាលបរិច្ឆេទនេះអាចផ្លាស់ប្តូរបានក្នុងករណីប្រធានស័ក្តិ។

**២. មហាសន្និបាតវិសាមញ្ញៈ** គឺត្រូវប្រារពធ្វើឡើងដោយពុំមានកាលបរិច្ឆេទកំណត់ច្បាស់លាស់នៅក្នុងលក្ខន្តិកៈឡើយ។ មហាសន្និបាតវិសាមញ្ញ គឺសំដៅធ្វើឡើងក្នុងករណីមានវិបត្តិសំរាប់ការដឹកនាំឬឧបសគ្គតានតឹងនានា ដែលមិនអាចដោះស្រាយបាននៅក្នុងក្រុមប្រឹក្សាភិបាល។ តែ

មហាសន្និបាតវិសាមញ្ញនឹងប្រព្រឹត្តទៅបានលុះត្រាតែមានការស្នើសុំដោយសំលេង ៥០%+១ នៃសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងសំលេង ១ភាគ៣ នៃសមាជិកទាំងអស់។

**៣. គណកម្មការរៀបចំមហាសន្និបាតៈ** មុននឹងរៀបចំមហាសន្និបាតរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពត្រូវបង្កើតគណៈកម្មការឯករាជ្យមួយដើម្បីដំណើរការរៀបចំ។ គណៈកម្មការឯករាជ្យនេះត្រូវមានសមាសភាពយ៉ាងច្រើន០៥រូប និងបំពេញភារកិច្ចមុនមហាសន្និបាតរយៈពេល១០ថ្ងៃ ហើយចប់ភារកិច្ចក្រោយមហាសន្និបាតរយៈពេល០៣ថ្ងៃ។ ប្រធាន និងសមាជិករបស់ គណៈកម្មការនេះត្រូវរើសចេញពីសមាជិកនិងបុគ្គលិកថ្នាក់ក្រោមរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព។

## មាត្រា ១០

ប្រធាន និង សមាជិកគណៈកម្មការរៀបចំមហាសន្និបាត គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនសមាជិកក្រុមប្រឹក្សាភិបាល និងប្រធានគណកម្មាធិការគ្រប់គ្រងបានឡើយ។ រៀងរាល់មហាសន្និបាតគណៈកម្មការ រៀបចំមហាសន្និបាតត្រូវតែអញ្ជើញអ្នកសង្កេតការណ៍ឯករាជ្យមកពីខាងក្រៅឲ្យចូលរួមសង្កេតការណ៍។ អ្នកសង្កេតការណ៍ទាំងអស់គ្មានសិទ្ធិបោះឆ្នោតឡើយ តែមានសិទ្ធិចូលរួមជាយោបល់ក្នុង មហាសន្និបាតបាន។

## មាត្រា ១១

មានតែមហាសន្និបាតរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពតែមួយគត់ដែលអាចធ្វើវិសោធនកម្មលក្ខន្តិកៈរបស់អង្គការមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពបានតែត្រូវឈរលើសំលេងយល់ព្រម ៥០%+១នៃសមាជិកចូលរួមក្នុងមហាសន្និបាតទាំងអស់។

## មាត្រា ១២

នីតិវិធីនៃការបោះឆ្នោតជ្រើសតាំងប្រធានមជ្ឈមណ្ឌល និងសមាជិកក្រុមប្រឹក្សាភិបាលត្រូវកំណត់ដោយគណៈកម្មាធិការរៀបចំការបោះឆ្នោត។

## ជំពូកទី៦

## អំពី
## ក្រុមប្រឹក្សាភិបាល

**មាត្រា ១៣**

ក្រុមប្រឹក្សាភិបាលត្រូវមានសមាសភាពពី៥ ទៅ ៩នាក់ដែលត្រូវបោះឆ្នោតជ្រើសតាំងដោយមហាសន្និបាត ។ ក្រុមប្រឹក្សាភិបាលមានអំណាចបញ្ញត្តិ និងមានអណត្តិរយៈពេលបួនឆ្នាំស្មើនឹងអណត្តិរបស់ប្រធានមជ្ឈមណ្ឌលដែរ ។

**មាត្រា ១៤**

ក្នុងករណីប្រធានក្រុមប្រឹក្សាភិបាលលាលែងពីតំណែងមុនអណត្តិ ឬបាត់បង់សុពលភាពដោយប្រការណា មួយសមាជិកក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំនិងបោះឆ្នោតជ្រើសតាំងសមាជិកណាម្នាក់ឲ្យធ្វើជាប្រធានបន្ត ។ ប៉ុន្តែក្នុងករណីប្រធានក្រុមប្រឹក្សាភិបាលអវត្តមានពីក្នុងប្រទេសតំណែងប្រធានក្រុមប្រឹក្សាភិបាលស្តីទីត្រូវផ្ទេរទៅឲ្យសមាជិក ដែលមានសំលេងឆ្នោតគាំទ្របន្ទាប់ជាស្វ័យប្រវត្តិ។ ឯការប្រជុំក្រុមប្រឹក្សាភិបាលត្រូវដឹកនាំដោយសមាជិកក្រុមប្រឹក្សាភិបាលណាដែលមានសំលេងឆ្នោតច្រើនជាងគេ។

ក្នុងករណីប្រធាន ឬសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ប្រព្រឹត្តិផ្ទុយពីលក្ខន្តិកៈរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំដើម្បីសំរេចព្យួរមុខតំណែងដើម្បីរងចាំមហាសន្និបាតជាអ្នកសំរេច។ ការសំរេចព្យួរមុខតំណែងត្រូវតែមានសំលេងគាំទ្រពីរភាគបីនៃសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ដែលមានវត្តមាននៅពេលប្រជុំ។

**មាត្រា ១៥**

ការបោះឆ្នោតអាចធ្វើឡើងដោយមានវត្តមានរឺគ្មានវត្តមានរបស់បេក្ខជនតាមបញ្ជីដែលបានកំណត់ដោយគណៈកម្មការជ្រើសរើស ឬពីសមាជិកនៃអង្គមហាសន្និបាត ។ ប៉ុន្តែការស្នើឈ្មោះបេក្ខជនត្រូវមានការយល់ព្រមពីសាមីខ្លួន និងការផ្តល់មូលហេតុពីអ្នកដែលស្នើសុំ។

**មាត្រា ១៦**

ការជ្រើសរើសប្រធានក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងដោយអង្គប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាភិបាលបន្ទាប់ពីមហាសន្និបាត។

**មាត្រា ១៧**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងបីដងក្នុងមួយឆ្នាំ ។ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំសមាជិកក្រុមប្រឹក្សាភិបាលលើកទីមួយយ៉ាងយូររយៈពេលមួយខែ បន្ទាប់ពីការបោះឆ្នោត ។

រាល់ការធ្វើសេចក្តីសំរេចរបស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវឈរលើកុងសង់ស៊ីស ។ ប៉ុន្តែបើពុំអាចរកកុងសង់ស៊ីសបានត្រូវឈរលើមតិភាគច្រើន ៥០%+១ ។ ក្នុងករណីមានការបែងចែកសំលេង ដោយសំលេងរបស់ប្រធានមានឧត្តមានុភាព។

## មាត្រា ១៨

តួនាទីសំខាន់ៗមួយចំនួនរបស់ក្រុមប្រឹក្សាភិបាលមានដូចតទៅ ៖

- ពិនិត្យមើលទៅលើគោលនយោបាយរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព
- អនុម័តគោលនយោបាយសំខាន់ៗមួយចំនួនរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាពមានជាអាទិគោលនយោបាលហិរញ្ញវត្ថុ គោលនយោបាយបុគ្គលិក ព្រមទាំងគោលគោលនយោបាយយេនឌ័រ ។
- ស្វែងរកជំនួយ និង ធ្វើការចចាជាមួយម្ចាស់មូលនិធិនានាដើម្បីជួយទ្រទ្រង់ដំណើរការនៃកម្មវិធីផ្សេងៗរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព។
- ត្រួតពិនិត្យ និងតាមដានសកម្មភាពការងារនិងការចំណាយប្រចាំថ្ងៃ ខែ និង ឆ្នាំរបស់គណកម្មាធិការគ្រប់គ្រង។
- ដោះស្រាយវិវាទដែលកើតឡើងរវាងបុគ្គលិកនិងប្រធានក្នុងករណីមិនអាចសំរបសំរួលគ្នាបាន ។

## ជំពូកទី៧
## អំពី
## គណកម្មាធិការគ្រប់គ្រង

## មាត្រា ១៩

សមាសភាពក្នុងគណកម្មាធិការគ្រប់គ្រងរួមមាន ៖

- ប្រធានចំនួន ០១រូប
- ប្រធានគ្រប់គ្រងកម្មវិធីចំនួន ០១រូប
- អគ្គហេរញ្ញិកចំនួន ០១រូប
- ប្រធានរដ្ឋបាលចំនួន ០១រូប

. ផ្នែកកម្មវិធីសំខាន់ៗ រួមមាន ៖

- អប់រំ និង ហ្វឹកហ្វឺន
- ផ្នែកតស៊ូមតិ និង បណ្តាញ
- ផ្នែកពត៌មាន និង បោះពុម្ព
- ផ្នែកសុខភាព និង គ្រឿងញៀន
- ផ្នែកប្រឆាំងការជួញដូរស្ត្រី
- សាខារាជធានី-ខេត្ត

## មាត្រា ២០

គណៈកម្មាធិការគ្រប់គ្រងគឺ ជាអ្នកទទួលខុសត្រូវអនុវត្តន៍កិច្ចការប្រចាំថ្ងៃ និងធានាឲ្យមានដំណើរល្អនៅក្នុងមជ្ឈមណ្ឌល។ គណៈកម្មាធិការគ្រប់គ្រងត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាភិបាលនិងមហាសន្និបាតរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពចំពោះសកម្មភាពការងាររបស់ខ្លួន ។

ក្នុងករណីប្រធានគណៈកម្មាធិការគ្រប់គ្រងប្រព្រឹត្តិផ្ទុយ ពីលក្ខន្តិកៈរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំដើម្បីសំរេចព្យួរមុខតំណែងដើម្បីរងចាំមហាសន្និបាតជាអ្នកសំរេច។ ការសំរេចព្យួរមុខតំណែងត្រូវតែមានសំលេងគាំទ្រពីរភាគបីនៃសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ដែលមានវត្តមាននៅពេលប្រជុំ។

## មាត្រា ២១

ការប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងគឺមានកិច្ចប្រជុំប្រចាំសប្តាហ៍ ប្រចាំខែ និងកិច្ចប្រជុំប្រចាំឆ្នាំ ។ ប្រធានជាអ្នកដឹកនាំការងារប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រង ។ករណីប្រធានអវត្តមានត្រូវផ្ទេរសិទ្ធិឲ្យនាយកគ្រប់គ្រងកម្មវិធី ឬ អ្នកទទួលខុសត្រូវតាមឋានានុក្រមបន្តបន្ទាប់ដើម្បីដឹកនាំការងារជំនួស ។

រាល់ការធ្វើសេចក្តីសំរេចរបស់គណៈកម្មាធិការគ្រប់គ្រងត្រូវឈរលើកុងសង់ស៊ីស។ ប៉ុន្តែបើពុំអាចរកកុងសង់ស៊ីសបានត្រូវឈរលើមតិភាគច្រើន៥០%+១។ ក្នុងករណីមានការបែងចែកសំលេងសំលេងរបស់ប្រធានមានឧត្តមានុភាព។

## មាត្រា ២២

ការជ្រើសរើសបុគ្គលិកអោយបំរើការងារឲ្យនៅក្នុងមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាពត្រូវធ្វើឡើងដោយការប្រលងសមត្ថភាពដោយស្មើភាព។ គោលការណ៍នៃការជ្រើសរើសនឹងមានចែងលំអិតក្នុងគោលនយោបាយដាច់ដោយឡែកមួយ ។

## ជំពូកទី៨
## អំពី
## បទវិន័យ

### មាត្រា ២៣

មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាពនឹងដាក់វិន័យដល់សមាជិកណា ដែលមិនគោរពលក្ខន្តិកៈ ឬលិខិតបទដ្ឋាននានារបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពដោយប្រការ ៖

- ការណែនាំដោយផ្ទាល់មាត់លើកទី១ ដោយគណកម្មាធិការគ្រប់គ្រង
- ការណែនាំជាលាយលក្ខអក្សរលើកទី២ ដោយគណកម្មាធិការគ្រប់គ្រង
- លើកទី៣ គឺដកសិទ្ធិសមាជិកភាព។ ការដាក់ពិន័យទាំងអស់ គឺត្រូវធ្វើឡើងដោយលាយលក្ខអក្សរដោយគណកម្មាធិការគ្រប់គ្រង។

### មាត្រា ២៤

សមាជិកគ្រប់រូបរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពមិនអាចយកឈ្មោះ ទង់ ផ្លាកសញ្ញា និង ត្រា របស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពទៅប្រើប្រាស់ក្នុងន័យបំរើគណបក្សនយោបាយ និងបុគ្គលខ្លួនជាដាច់ខាត ។ ក្នុងករណីប្រព្រឹត្តខុសពីលក្ខន្តិកៈនឹងដាក់វិន័យដូចមាត្រា១៩។

### មាត្រា ២៥

បុគ្គលិក និងសមាជិកសមាជិការបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពអាចបញ្ចេញទស្សនៈរិះគន់ និងសួរដេញដោលពីបញ្ហាដែលមានមន្ទិលសង្ស័យដោយសេរី ។ ការបញ្ចេញមតិរីទស្សនៈរិះគន់ និងសួរដេញដោលនេះនឹងមិនត្រូវបានដកហូតពីដំណែង ឬទទួលការព្រមានណាមួយឡើយ ។ ផ្ទុយទៅវិញបើបុគ្គលិក ឬសមាជិកណាមានបញ្ហាហើយមិនបានលើកឡើងក្នុងអង្គប្រជុំ បែរជាយកទៅនិយាយខាងក្រៅនោះនឹងត្រូវដកហូត ឬព្រមានទៅតាមកំរិតនៃកំហុសឆ្គង។

## ជំពូកទី៩
## អំពី
## ប្រភពមូលនិធិ និង ការប្រើប្រាស់

### មាត្រា ២៦

មូលនិធិរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាពបានមកពី ៖

- ការបង់វិភាគទានពីសមាជិក។

- អំណោយផ្សេងៗជាអំណោយសប្បុរសធម៌ពីអង្គការជាតិ និង អន្តរជាតិនានា។
- ជំនួយផ្សេងៗ ដែលអង្គការម្ចាស់មូលនិធិផ្តល់អោយតាមកិច្ចព្រមព្រៀងលើកម្មវិធីនានាជាមួយមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព។

មាត្រា ២៧

រាល់ការចាយវាយនិងការប្រើប្រាស់ថវិការបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាពត្រូវមានផែនការគោលការណ៍ច្បាស់លាស់ និងមានតម្លាភាពប្រកបទៅដោយស្មារតីសន្សំសំចៃ ហើយការចំណាយនោះមានផលប្រយោជន៍ចំពោះមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព។ រាល់ការចាយវាយនានាត្រូវរាយការណ៍ជូនមហាសន្និបាត អង្គប្រជុំប្រចាំខែ និងសន្និបាតប្រចាំឆ្នាំ។

**មាត្រា ២៨**

ហេរញ្ញិកមានតួនាទីគ្រប់គ្រងចំនួនទឹកប្រាក់ និងសាច់ប្រាក់ដោយផ្ទាល់តែគ្មានសិទ្ធិបញ្ជាចំណាយឡើយ។ មានតែអាណាប័ក ឬអាណាប័កផ្ទេរសិទ្ធិប៉ុណ្ណោះ ដែលមានសិទ្ធិបញ្ជាចំណាយ ហើយការចំណាយទាំងនោះត្រូវស្របទៅនឹងកម្មវិធីរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព។

## ជំពូកទី១០
## អំពី
## គោលការណ៍ និងការដឹកនាំ

**មាត្រា ២៩**

គោលការណ៍របស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពមានបីចំណុចគឺ:

១. ប្រឆាំងការប្រើប្រាស់គ្រឿងញៀនគ្រប់ប្រភេទព្រមទាំង ស្រានិងបារី
២. ការចូលរួម និងតម្លាភាព
៣. សមភាពយេនឌ័រ Gender

**មាត្រា ៣០**

លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សគឺជាមូលដ្ឋានគ្រឹះក្នុងការដឹកនាំនិងអភិវឌ្ឍន៍មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព ។ គោលការណ៍ទាំងឡាយណាដែលប្រាសចាកពីគោលការណ៍ប្រជាធិបតេយ្យនឹងមិនត្រូវបានយកមកធ្វើជាមូលដ្ឋាននៃការដឹកនាំសំរាប់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពជាដាច់ខាត ។

**មាត្រា ៣១**

មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពត្រូវជំរុញអោយមានគោលការណ៍ប្រជាធិបតេយ្យនៅគ្រប់ជាន់ថ្នាក់នៃរចនាសម្ព័ន្ធដឹកនាំនិងគ្រប់សកម្មភាពទាំងអស់របស់ខ្លួន។ គ្មានជនណាម្នាក់អាចធ្វើការផ្លាស់ប្តូរគោលកាណ៍ខាងនេះបានឡើយ ។

## ជំពូកទី១១
## អំពី
## អធិបតេយ្យភាព

**មាត្រា ៣២**

មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពជាអង្គការឯករាជ្យពីគណបក្សនយោបាយនានា និង ពីរដ្ឋាភិបាល ដូចនេះ ប្រធាន សមាជិកក្រុមប្រឹក្សាភិបាល និង បុគ្គលិកគ្រប់លំដាប់ថ្នាក់ ដែលកំពុងប្រតិបត្តិនិងបំពេញមុខនាទីក្នុងមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពមិនអាចជាសមាជិកសកម្មនៃគណបក្សនយោបាយ និងជាសមាជិកនៃគណៈរដ្ឋមន្ត្រី ដែលកំពុងកាន់អំណាចឡើយ ។ ហើយបុគ្គលិកទាំងអស់ត្រូវតែប្រកាន់ជំហរអព្យាក្រិតក្នុងពេលបំពេញភារកិច្ចរបស់ខ្លួនក្នុងនាមមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាពផងដែរ។

**មាត្រា ៣៣**

ទង់ និង ផ្លាកសញ្ញារបស់ មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពមានកំនត់នៅក្នុងឧបសម្ព័ន្ធ ១ និង ២ ។

មាត្រា ៣៤

ទីស្នាក់ការកណ្តាលរបស់ មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពតាំងនៅរាជធានីភ្នំពេញ ។

## ជំពូកទី១២
## អំពី
## ការរំលាយមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព

**មាត្រា ៣៥**

មានតែមហាសន្និបាតរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាពតែមួយគត់ដែលមានសិទ្ធិរំលាយមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាពនេះបានដោយឈរលើសំលេងភាគច្រើនដាច់ខាត ២ភាគ៣។

**មាត្រា ៣៦**

បន្ទាប់ពីត្រូវបានរំលាយ ទ្រព្យសម្បត្តិ និងសារពើភ័ណ្ឌរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាពទាំងអស់ត្រូវធ្វើជាអំណោយដល់សមាគម ឬអង្គការសប្បុរសធម៌នានាទៅតាម ការសំរេចដោយមតិភាគច្រើន (៥០%+១) នៃក្រុមប្រឹក្សាភិបាល។

## ជំពូកទី១៣
## អំពី
## អន្តរបញ្ញត្តិ

**មាត្រា ៣៧**

លក្ខន្តិកៈនេះក្រោយពីបានធ្វើការអនុម័តត្រូវប្រកាសឲ្យចូលជាធរមានភ្លាមដោយអង្គមហាសន្និបាត និង ចុះហត្ថលេខាដោយប្រធានគណកម្មាធិការគ្រប់គ្រង។

**មាត្រា ៣៨**

លិខិតបទដ្ឋានទាំងឡាយនៅមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព ដែលធានាការពារនូវទ្រព្យសម្បត្តិ សិទ្ធិសេរីភាព និង ផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់របស់សមាជិកមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាពត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោលឬលើកលែងតែបទបញ្ញត្តិណា ដែលផ្ទុយនឹងស្មារតីនៃលក្ខន្តិកៈនេះ។

លក្ខន្តិកៈនេះត្រូវបានមហាសន្និបាតលើកទី១របស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាពអនុម័តនៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៥

**ជ.មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព**

**ប្រធាន**

**យង់ គិមអេង**

លក្ខន្តិកៈនេះត្រូវបានអង្គមហាសន្និបាតលើកទី៥ ធ្វើវិសោធនកម្មត្រង់ **មាត្រា៣** ចំនុច **ឃ** នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៦ ។

ខេត្តព្រះសីហានុ, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៦

**ជ.មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព**

**ប្រធាន**

**យង់ គិមអេង**